ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌលេខៈ១៦២២ អ.ក
ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩
សាលក្រមលេខៈ ២៧១ (ថ)
ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្តាល

-បានបើកកិច្ចពិភាក្សាដេញដោលជាសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ ដោយមានសមាសភាពដូចខាងក្រោមៈ

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជម្រះ នៃសាលាដំបូងខេត្តកណ្តាល

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

**មេធាវី**

លោក [redacted] និងលោក [redacted] ការពារសិទ្ធិឱ្យជនជនជាប់ចោទឈ្មោះ[redacted]នឿន

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌៈ ១៦២២ អ.ក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទឈ្មោះ[redacted] នឿន ភេទប្រុស អាយុ៤៤ឆ្នាំ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន ភូមិ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ[redacted]ញ៉ៅ (រស់) ម្តាយឈ្មោះ[redacted]ហ៊ាង (រស់) ប្រពន្ធឈ្មោះ[redacted]សុខគីម មានកូន០៦នាក់ ជានីតិជន ទោសពីមុនគ្មាន (ក្រៅឃុំ)

ជាប់ចោទពីបទៈ ឆបោក ប្រព្រឹត្តនៅភូមិល្វាទោង ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ប៊ុនថេង ភេទប្រុស អាយុ៤៩ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិវីប៉ោ ឃុំស្វាយពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

-បានឃើញមាត្រា ២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រាបន្តបន្ទាប់។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ**

កាលថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ឈ្មោះ[redacted]នឿន ភេទប្រុស អាយុ៤៤ឆ្នាំ បានសុំការងាររបស់ឈ្មោះ[redacted]ប៊ុនថេង ភេទប្រុស រៀបចំដីមួយកន្លែងស្ថិតនៅចំណុចភូមិល្វាទោង ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល ចំនួន១០ ទៅ ២០ ហិចតា ក្នុងមួយហិចតាតម្លៃ២៤៥០ ដុល្លារអាមេរិក ដោយឈ្មោះ[redacted] នឿន អះអាងថា អាចទិញបានបន្ទាប់មកក្រុមការងាររបស់ឈ្មោះ [redacted] ប៊ុនថេង បានឯកភាពព្រមព្រៀងឱ្យឈ្មោះ[redacted] នឿន រៀបចំដីដែលមានទីតាំងដូចខាងលើដោយបានកក់ប្រាក់ចំនួន ១១០០០ ដុល្លារអាមេរិក ឱ្យទៅឈ្មោះ[redacted]នឿន។ លុះក្រោយមកក្រុមការងាររបស់ឈ្មោះ [redacted] ប៊ុនថេង បានទៅសាកសួរប្រជាពលរដ្ឋ និង



Scanned with CamScanner

អាជ្ញាធរក៏បានដឹងថា ឈ្មោះ [redacted] នឿន ពុំមានដីនៅទីនោះទេ ដោយដីដែលឈ្មោះ [redacted] នឿន ចង្អុលប្រាប់ទៅក្រុមការងាររបស់ឈ្មោះ [redacted] ប៊ុនថេង គឺជាដីបាតបឹងរបស់រដ្ឋ មិនមែនជាដីរបស់ឈ្មោះ [redacted] នឿន ទេ ដោយមានសាក្សីឈ្មោះ [redacted] រ៉ា ភេទប្រុស និងឈ្មោះ [redacted] យ៉ុន ភេទប្រុស បានបញ្ជាក់ថា ដីដែលឈ្មោះ [redacted] នឿន ចង្អុលនោះ គឺជាដីបាតបឹងរបស់រដ្ឋ។

-ក្រោយពីបានធ្វើកិច្ចពិភាក្សាដេញដោល
-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី
-ក្រោយពីបានពិនិត្យឯកសារនានានៅក្នុងសំណុំរឿង
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
-ក្រោយពីបានពិនិត្យ និងពិចារណាតាមផ្លូវច្បាប់រួចរាល់ហើយ

**<u>សាលាដំបូងខេត្តកណ្តាល</u>**
**<u>យល់ឃើញថា</u>**

១-តាមចម្លើយរបស់ជនជាប់ចោទ អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី អំណានចម្លើយរបស់សាក្សី និងតាមការពិនិត្យឯកសារ និងភស្តុតាងនានានៅក្នុងសំណុំរឿងឃើញថា ពុំមានអង្គហេតុដូចការចោទប្រកាន់របស់តំណាងអយ្យការ ដែលបានចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] នឿន ពីបទ៖ ឆបោក ប្រព្រឹត្តនៅភូមិល្វាទោង ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ នោះទេ។

២-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] នឿន ៖ យោងតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] នឿន ដែលបានឆ្លើយនៅក្នុងនីតិវិធីនៃការពិភាក្សាដេញដោលថា កាលពីឆ្នាំ២០១៨ ខ្លួនបានទិញដីពីប្រជាពលរដ្ឋបានចំនួន ១៥ ហិកតា ស្ថិតនៅភូមិល្វាទោង ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល ដើម្បីលក់ទៅឱ្យឈ្មោះ ឆេង យ៉ុន ។ ហើយឈ្មោះ ឆេង យ៉ុន បានកក់ប្រាក់ចំនួន ១១០០០ (មួយម៉ឺនមួយពាន់) ដុល្លារអាមេរិក មកខ្លួន ហើយខ្លួនបានយកលុយទាំងនោះទៅកក់ថ្លៃដីជូនប្រជាពលរដ្ឋទាំងអស់។ លុះដល់ពេលកំណត់ទូទាត់លុយថ្លៃដីបង្គ្រប់ឈ្មោះ [redacted] យ៉ុន មិនមានប្រាក់មកទូទាត់បង្គ្រប់ឱ្យប្រជាពលរដ្ឋទេ ទើបគាត់សុំពន្យាពេលរហូត ដោយមិនបានធ្វើកិច្ចសន្យាទេ ធ្វើឱ្យប្រជាពលរដ្ឋខឹងក៏នាំគ្នាផ្តាច់ប្រាក់កក់តែម្តង។ ចំពោះរឿងខ្លួនបានដោះស្រាយទូទាត់លុយទៅដើមបណ្តឹងរួចរាល់ហើយ ហើយដើមបណ្តឹងរដ្ឋប្បវេណីក៏បានដាក់ពាក្យសុំដកពាក្យបណ្តឹងផងដែរ។

ជនជាប់ចោទឈ្មោះ [redacted] នឿន ត្រូវបានតំណាងអយ្យការ និង ចៅក្រមស៊ើបសួរបញ្ជូនមក ធ្វើការជំនុំជម្រះ ពីបទ៖ ឆបោក ប្រព្រឹត្តនៅភូមិល្វាទោង ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល។ ចំពោះអង្គហេតុដែលចោទប្រកាន់ គឺយោងតាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយរបស់សាក្សីឈ្មោះ [redacted] រ៉ា និងឈ្មោះ [redacted] យ៉ុន ប៉ុន្តែផ្អែកតាមចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់សាក្សីឈ្មោះ [redacted] សារុំ ឈ្មោះ [redacted] ស្រ៊ា ឈ្មោះ [redacted] ម៉េក ឈ្មោះ [redacted] ធូ ឈ្មោះ [redacted] ហៃ និងឈ្មោះ [redacted] យាន និងការពិនិត្យឯកសារនានាក្នុងសំណុំរឿង



Scanned with CamScanner

ឃើញថា អង្គនេះគឺជាវិវាទកិច្ចសន្យាទិញលក់ដី ដែលកើតចេញពីការមិនអនុវត្តតាមកិច្ចសន្យា តុលាការយល់ឃើញថា មិនមានអំពើល្មើសដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ។

៣-ធាតុអត្ថនោម័តរបស់ជនជាប់ចោទឈ្មោះ [redacted] នឿន ៖ តាមចម្លើយរបស់ជនជាប់ចោទផ្ទាល់នៅក្នុងដំណាក់កាលនៃកិច្ចពិភាក្សាដេញដោល គឺជនជាប់ចោទបានឆ្លើយថា កាលពីឆ្នាំ២០១៨ ខ្លួនបានទិញដីពីប្រជាពលរដ្ឋបានចំនួន ១៥ ហិកតា ស្ថិតនៅភូមិល្វាទង ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល ដើម្បីលក់ទៅឱ្យឈ្មោះ [redacted] យ៉ុន ។ ហើយឈ្មោះ [redacted] យ៉ុន បានកក់ប្រាក់ចំនួន ១១០០០ (មួយម៉ឺនមួយពាន់) ដុល្លារអាមេរិកមកខ្លួន ហើយខ្លួនបានយកលុយទាំងនោះទៅកក់ថ្លៃដីជូនប្រជាពលរដ្ឋទាំងអស់។ លុះដល់ពេលកំណត់ទូទាត់លុយថ្លៃដីបង្គ្រប់ឈ្មោះ [redacted] យ៉ុន មិនមានប្រាក់មកទូទាត់បង្គ្រប់ឱ្យប្រជាពលរដ្ឋទេ ទើបគាត់សុំពន្យាពេលរហូត ដោយមិនបានធ្វើកិច្ចសន្យាទេ ធ្វើឱ្យប្រជាពលរដ្ឋខឹងក៏នាំគ្នាផ្តាច់ប្រាក់កក់តែម្តង។ ចំពោះរឿងខ្លួនបានដោះស្រាយទូទាត់លុយទៅដើមបណ្តឹងរួចរាល់ហើយ ហើយដើមបណ្តឹងរដ្ឋប្បវេណីក៏បានដាក់ពាក្យសុំដកពាក្យបណ្តឹងផងដែរ។ ជនជាប់ចោទផ្ទាល់ មិនចេតនាទុច្ចរិតក្នុងការឆបោកយកលុយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនថេង នោះទេ តែដោយសារតែមានការខកខានក្នុងការអនុវត្តកិច្ចសន្យាទិញលក់ដី ទើបធ្វើឱ្យមានការយល់ច្រឡំជាមួយគ្នា។ ហើយក្រោយពីមានបញ្ហាកើតឡើង ជនជាប់ចោទក៏បានព្យាយាមរកដំណោះស្រាយ និងបានប្រគល់លុយកក់ថ្លៃដីទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីរួចរាល់ដែរ។ សកម្មភាពទាំងនេះ គឺអាចបញ្ជាក់ថា ជនជាប់ចោទមិនមានចេតនាប្រព្រឹត្តចំពោះអំពើល្មើសរបស់ខ្លួនឡើយ។

៤-ពុំមានធាតុផ្សំនៃបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់ ដើម្បីផ្តន្ទាទោសទៅលើជនជាប់ចោទឈ្មោះ [redacted] នឿន ពីបទៈ ឆបោក ប្រព្រឹត្តនៅភូមិល្វាទង ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ នោះទេ តុលាការយល់ឃើញថា រឿងនេះជាវិវាទកិច្ចសន្យាកិច្ចសន្យា មិនចូលបទល្មើសព្រហ្មទណ្ឌទេ គប្បីតុលាការសម្រេចឱ្យឈ្មោះ [redacted] នឿន ភេទប្រុស អាយុ៤៨ឆ្នាំ រួចខ្លួន ពីបទៈ ឆបោក ប្រព្រឹត្តនៅភូមិល្វាទង ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ យោងតាមមាត្រា ៣៥០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៥-ការសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការថា ក្រោយពិភាក្សាដេញដោល ជនជាប់ចោទបានឆ្លើយថា មិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ អយ្យការនៅតែរក្សាការចោទប្រកាន់ដូចក្នុងដីការសន្និដ្ឋានស្ថាពរលេខ ១១២២ ដកសព ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ និងសូមតុលាការសម្រេចតាមច្បាប់។

តំណាងអយ្យការប្តឹងសុំ៖ សុំឱ្យរក្សាការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] នឿន ដូចក្នុងដីកាសន្និដ្ឋានស្ថាពរ និងសុំឱ្យផ្តន្ទាទោសលើជនជាប់ចោទ។ ចំពោះការប្តឹងសុំរបស់តំណាងអយ្យការលើចំណុចនេះ តុលាការបាន យល់ឃើញដូចមាននៅក្នុងចំណុចទី២ ចំណុចទី៣ និងចំណុចទី៤ នៃផ្នែកសំអាងហេតុ នៃសាលក្រមនេះ។

៦-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានធ្វើការពិភាក្សាដេញដោលរួចមកឃើញថា យោងតាមការអះអាងរបស់កូនក្តីខ្លួនគឺមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ យោងតាមអង្គហេតុ អង្គច្បាប់ និងភស្តុតាង បញ្ជាក់ឱ្យឃើញថា រឿងនេះកើតចេញពីវិវាទកិច្ចសន្យាទិញលក់ដី មិនមែនជាបទល្មើសព្រហ្មទណ្ឌទេ ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់ ដោយហេតុថា កូនក្តីខ្លួនមិនមានចេតនា ឬមានគំនិតដោយប្រើឧបាយកលទុច្ចរិតណាមួយក្នុងការឆបោកយកប្រាក់នោះទេ។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានទទួលស្គាល់ថាការ



Scanned with CamScanner

ប្តឹងនេះ គឺកើតចេញពីការយល់ច្រឡំជាមួយគ្នានៅក្នុងការអនុវត្តកិច្ចសន្យាទិញលក់ដីដែរ ហើយដើមបណ្តឹងក៏បានព្រមព្រៀងទទួលយកប្រាក់កក់ពីឈ្មោះ ឈ្មោះ [redacted] នឿន ដើម្បីបញ្ចប់វិវាទនេះដែរ និងបានដកពាក្យបណ្តឹងឈប់ប្តឹងកូនក្តីខ្លួនក្នុងសំណុំរឿងនេះរួចរាល់ហើយដែរ។ ដូចនេះសូមឱ្យតុលាការពិនិត្យ និងសម្រេចឱ្យកូនក្តីខ្លួន ឈ្មោះ [redacted] នឿន រួចផុតពីបទចោទទៅតាមផ្លូវច្បាប់ ដោយក្តីអនុគ្រោះ។ ចំពោះការប្តឹងសុំរបស់មេធាវីលើចំណុចនេះ តុលាការបានយល់ឃើញដូចមាននៅក្នុងចំណុចទី២ ចំណុចទី៣ និងចំណុចទី៤ នៃផ្នែកសំអាងហេតុនៃសាលក្រមនេះ។

៧-យោងតាមពាក្យសុំដកពាក្យបណ្តឹង ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ហង្ស ប៊ុនថេង បានដកពាក្យបណ្តឹងឈប់ប្តឹងលើឈ្មោះ [redacted] នឿន តទៅទៀតហើយ ដូចនេះតុលាការមិនពិចារណាពីសំណងរដ្ឋប្បវេណីទេ។

៨-ជនជាប់ចោទឈ្មោះ [redacted] នឿន សំណូមពរសូមឱ្យតុលាការលើកលែងទោស តុលាការបានយល់ឃើញដូចមាននៅក្នុងចំណុចទី២ ចំណុចទី៣ ចំណុចទី៤ និងចំណុចទី៧ នៃផ្នែកសំអាងហេតុ នៃសាលក្រមនេះ។

៩-យល់ឃើញថា ចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] នឿន លេខ ៣០៧ ដកបចខ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ តែដើមបណ្តឹងរដ្ឋប្បវេណីបានដកពាក្យបណ្តឹងឈប់ប្តឹងជនជាប់ចោទទៀតហើយ គប្បីតុលាការសម្រេចចេញដីកាបញ្ឈប់ចាប់ខ្លួនឈ្មោះ [redacted] នឿន ។

## ហេតុដូចនេះសាលាដំបូងខេត្តកណ្តាល

## វិនិច្ឆ័យសេចក្តី

១-ឱ្យឈ្មោះ [redacted] នឿន ភេទប្រុស អាយុ៤៤ឆ្នាំ ដែលមានសាវតាជាតិដូចខាងលើ រួចខ្លួន ពីបទៈ ឆបោក ប្រព្រឹត្តនៅភូមិល្វាទោង ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

២-ចេញដីកាបញ្ឈប់ចាប់ខ្លួនឈ្មោះ [redacted] នឿន ភេទប្រុស អាយុ៤៤ឆ្នាំ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ញ៉ែ (រស់) ម្តាយឈ្មោះ [redacted] ហ៊ាង (រស់) ប្រពន្ធឈ្មោះ [redacted] សុខគីម មានកូន០៦នាក់ ជានីតិជន ទោសពីមុនគ្មាន។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

-ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា៖ [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា៖ [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃ.............ខែ.......ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
កណ្តាល,ថ្ងៃទី......ខែ........ឆ្នាំ២០២០
**ក្រឡាបញ្ជី**
[redacted]

បានឃើញ
**ចៅក្រមជំនុំជម្រះ**
[redacted]



Scanned with CamScanner